**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ១៨ **អយក.** សណន

# សេចក្តីណែនាំ
# ស្តីពី
# ការលើកកម្ពស់សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាព នៅតាមគ្រឹះស្ថានសិក្សាសាធារណ: និងឯកជន

កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំលេខ ៣៦៣៧ អយក សណន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការលើកកម្ពស់សុខភាព អនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀននៅទូទាំងប្រទេស ហើយបានសង្កេតឃើញថា មានគ្រឹះស្ថានសិក្សាជាច្រើនបានអនុវត្តសេចក្តីណែនាំនេះបានល្អប្រសើរ តែនៅមានគ្រឹះស្ថានសិក្សាមួយចំនួនទៀតអនុវត្តមិនទាន់បានល្អប្រសើរនៅឡើយ ជាពិសេសការគ្រប់គ្រងនិងត្រួតពិនិត្យការលក់ចំណីអាហារនៅក្នុងបរិវេណគ្រឹះស្ថានសិក្សាដោយខ្វះការទទួលខុសត្រូវ គ្មានអនាម័យ គ្មានសុវត្ថិភាព និងគ្មានសុខុមាលភាពដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពនិងជំងឺផ្សេងៗ។

ដើម្បីពង្រឹងការអនុវត្តសេចក្តីណែនាំដែលបានដាក់ឱ្យអនុវត្តនៅគ្រប់គ្រឹះស្ថានសិក្សាកន្លងមកឱ្យកាន់តែមានប្រសិទ្ធភាព និងដើម្បីកាត់បន្ថយបាតុភាពអសកម្មនានា នៅតាមគ្រឹះស្ថានសិក្សាសាធារណ: និងឯកជននៅទូទាំងប្រទេស ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំអនុវត្តដូចខាងក្រោម ៖

១. គណ:គ្រប់គ្រងគ្រឹះស្ថានសិក្សានីមួយៗ មានភារកិច្ចទទួលខុសត្រូវក្នុងការកំណត់ទីតាំងលក់ចំណីអាហារគ្រប់ប្រភេទឱ្យមានសណ្តាប់ធ្នាប់ មានអនាម័យ មានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ ហើយត្រូវរៀបចំកន្លែងលក់លើទីតាំងខ្ពស់ស្អាត ផុតពីដី ឆ្ងាយពីបង្គន់ គំនរសំរាម ភក់ជ្រាំ លូទឹកស្អុយ និងឆ្ងាយពីបន្ទប់រៀន ឬច្រកចេញចូល។

២. គណ:គ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវរៀបចំបទបញ្ជាផ្ទៃក្នុង ស្តីពីសុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាព ជាលាយលក្ខណ៍អក្សរសម្រាប់បិទផ្សាយនៅកន្លែងលក់ចំណីអាហារ និងចែកដល់អ្នកលក់ទាំងនោះដោយផ្តោតសំខាន់លើចំណុចដូចខាងក្រោម ៖

ក). អាហារដ្ឋាន តូប រោង គ្រែ តុ កៅអី និងគ្រឿងឧបភោគ បរិភោគទាំងអស់ ដែលប្រើប្រាស់ក្នុងការលក់ចំណីអាហារត្រូវស្អាតជានិច្ច។ ចំណីអាហារដែលដាក់លក់ត្រូវមានគម្របការពារសត្វល្អិត រុយ កន្លាត និងធូលីជាដើម ដែលជាប្រភពចម្លង faith ជំងឺផ្សេងៗ។

ខ. ហាមដាច់ខាតចំពោះការលក់ចំណីអាហារដូចខាងក្រោម ៖

- ចំណីអាហារដែលមានជាតិប្រៃខ្លាំង ជាតិខ្លាញ់ច្រើន និងជាតិស្ករច្រើន
- ចំណីអាហារមិនបានចម្អិន ឬចម្អិនមិនបានត្រឹមត្រូវ ឬប្រើទឹកមិនស្អាត
- បន្លែ ផ្លែឈើ ដែលគ្មានអនាម័យ ឬខូចគុណភាព
- ចំណីអាហារកញ្ចប់ ឬកំប៉ុងហួសកាលកំណត់ប្រើប្រាស់ ចំណីអាហារដូរផ្អូម អាហារសល់ អាហារត្រាំទឹកអំបិល ឬទឹកស្ករជាដើម
- ចំណីអាហារប្រើមេស្ករ ល័ក្តពណ៌ មេទឹកខ្មេះ និងសារធាតុគីមីពុលផ្សេងៗ សម្រាប់ធ្វើឱ្យអាហារស្វិត ភ្លឺ ឬពណ៌ស្រស់ទុកបានយូរ។

គ. ការលក់ចំណីអាហារដូចជា គ្រឿងត្រាំ គ្រឿងជ្រលក់ កន្ទួតត្រាំ ស្វាយត្រាំ គ្រឿងម្ជូរ ត្រូវធានាគុណភាព អនាម័យ និងត្រូវមានការត្រួតពិនិត្យ។

ឃ. យកចិត្តទុកដាក់លក់ចំណីអាហារជាមូលដ្ឋានដែលបម្រើដល់សុខុមាលភាពសិស្សដូច ជាបាយ នំប៉ុង មី បបរ និងបង្អែម ផ្លែឈើ ប្រកបដោយគុណភាព និងអនាម័យខ្ពស់។

៣. គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវ ៖

- ចាត់ឱ្យមានការតាមដាន និងប្រជុំណែនាំតាមពេលវេលាជាក់ស្តែងដល់អ្នកលក់ចំណីអាហារទាំងនោះ ទាំងនៅក្នុងបរិវេណ និងនៅជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សា ដើម្បីឱ្យគេបានយល់ដឹងអំពីការរួមចំណែករបស់គេតាមរយៈការរៀបចំណីអាហារដែលមានសុវត្ថិភាព និងសុខុមាលភាព ជួយដល់ការសិក្សារបស់សិស្ស។
- ចាត់វិធានការដោយធ្វើកិច្ចសន្យា ស្តីពីការអនុវត្តសុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាព ចំពោះអ្នកលក់ចំណីអាហារនៅក្នុងបរិវេណគ្រឹះស្ថានសិក្សាទាំងអស់។ វិធានការនេះ ត្រូវរៀបចំធ្វើផងដែរចំពោះការលក់ដូរចំណីអាហារនៅខាងក្រៅជាប់បរិវេណគ្រឹះស្ថានសិក្សា ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅតាមមូលដ្ឋាន។
- ក្នុងករណីរកឃើញថា អ្នកលក់ចំណីអាហារណាដែលបំពាននិងមិនបានអនុវត្តតាមការណែនាំ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវហាមឃាត់ជាបន្ទាន់នូវការលក់ដូរទាំងនោះ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ។

៤. គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សានីមួយៗ ត្រូវចាត់តាំងឱ្យមានអ្នកត្រួតពិនិត្យអនាម័យនៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន។ អ្នកត្រួតពិនិត្យអនាម័យមានភារកិច្ចត្រួតពិនិត្យជាប្រចាំ លើសណ្តាប់ធ្នាប់ ការដាក់លក់ និងគុណភាពចំណីអាហារ ហើយរាយការណ៍ជូន បណ្តាញសមត្ថកិច្ចសុខភាព ដើម្បីឱ្យជួយអន្តរាគមន៍ទាន់ពេលវេលា បើសង្កេតឃើញមានជំងឺឆ្លងនៅតាម

បរិវេណគ្រឹះស្ថានសិក្សាដែលបណ្តាលមកពីទឹក ចំណីអាហារ ឬដោយកត្តាផ្សេងៗ។

៥. គ្រូទទួលបន្ទុកថ្នាក់និងគ្រូបង្រៀនមុខវិជ្ជាពាក់ព័ន្ធត្រូវអប់រំអំពីសុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាព ព្រមទាំងអនាម័យទូទៅតាមពេលវេលាសមស្របក្នុងនោះត្រូវផ្តោតទៅលើអនាម័យខ្លួនប្រាណ អនាម័យចំណីអាហារ អនាម័យទីធ្លា គ្រឹះស្ថានសិក្សា បង្គន់ ។ល។ ដោយឡែក លោកគ្រូ អ្នកគ្រូត្រូវពិនិត្យលទ្ធភាពរៀបចំឱ្យមានទឹកស្អាតសម្រាប់បរិភោគនៅតាមគ្រឹះស្ថានសិក្សា ឬអាចណែនាំសិស្សឱ្យយកទឹកស្អាត និងចំណីអាហារពីផ្ទះទុកសម្រាប់ហូបនៅតាមគ្រឹះស្ថានសិក្សា ដើម្បីធានាសុវត្ថិភាពចំណីអាហារផ្ទាល់ខ្លួនរបស់គេម្នាក់ៗ។

ក្រសួងសង្ឃឹមលើស្មារតីទទួលខុសត្រូវខ្ពស់របស់លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡាគ្រប់រាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងនាយក នាយិកា លោកគ្រូ អ្នកគ្រូ នៅគ្រប់គ្រឹះស្ថានសិក្សាក្នុងការធ្វើឱ្យសម្រេចតាមសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ។

សូមលោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**ស៊ាន-បូរ៉ាត**

**<u>ចម្លងជូន</u>**

- គ្រប់ក្រសួងពាក់ព័ន្ធ
  *"ដើម្បីជូនជ្រាប និងសហការ"*
- សាលារាជធានី ខេត្ត *"ដើម្បីជូនជ្រាប"*
- អង្គភាពពាក់ព័ន្ធ *"ដើម្បីមុខការ"*
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  *"ដើម្បីផ្សព្វផ្សាយនិងអនុវត្តបន្ត"*
- កាលប្បវត្តិ
- ឯកសារ នសស